# បញ្ហាប្រឈមសំខាន់ៗក្នុងការអភិវឌ្ឍប្រទេសកម្ពុជា[1]

ដោយលោកបណ្ឌិត **ហ្វូសេន ចេលីលាន**
នាយកផ្នែកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI

## សាវតា

ប្រទេសកម្ពុជាសំរេចបានអត្រាកំណើនសេដ្ឋកិច្ចយ៉ាងខ្ពស់ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ ព្រមគ្នានេះ ក៏មានការថយចុះអត្រាភាពក្រីក្រគួរឱ្យកត់សំគាល់ ។ ទោះជាយ៉ាងនេះ អត្រាភាពក្រីក្រនៅតែមានកំរិតខ្ពស់ និងនៅតែជាបញ្ហាប្រឈមចំបងមួយសំរាប់ប្រទេសកម្ពុជា ។ មានការពិភាក្សាដេញដោលថា តើកម្ពុជាគួរតែធ្វើបានប្រសើរជាងនេះក្នុងការកាត់បន្ថយភាពក្រីក្រ រឺយ៉ាងណា ។ ទាក់ទងនឹងបញ្ហានេះ មានការបារម្ភកាន់តែច្រើនថា វិសមភាពនៅកម្ពុជាបានកើនឡើង ។ ការសិក្សាថ្មីៗជាច្រើនដែលវិទ្យាស្ថាន CDRI បានបោះពុម្ពផ្សាយ[២] រួមជាមួយនឹងរបាយការណ៍សមធម៌របស់ធនាគារពិភពលោកនៅឆ្នាំ២០០៧ បានគាំទ្រដល់មតិដែលថា វិសមភាពនៅកម្ពុជាបានកើនឡើងនៅអំឡុងពេលថ្មីៗនេះ ។ ជាពិសេស ការសិក្សារបស់វិទ្យាស្ថាន CDRI ក៏បានផ្តល់ភស្តុតាងថា អ្នកក្រីក្រមិនបានទទួលផលចំណេញច្រើនទេ ពីកំណើនសេដ្ឋកិច្ចដ៏ខ្ពស់នេះ ។ ទោះបីជាវាមិនមានជាសញ្ញាត្រូវតែបារម្ភក្តី ប៉ុន្តែវាមានសារៈសំខាន់គួរពិនិត្យមើលដោយប្រយ័ត្នប្រយែងពីមូលហេតុចំបងចំពោះនៃជោគជ័យដែលមានកំរិតនេះ ក្នុងការកាត់បន្ថយភាពក្រីក្រ និងវិសមភាព ។

នៅក្នុងបទបង្ហាញនេះ ខ្ញុំសូមបង្ហាញជូនដោយត្រួសៗពី កត្តាមួយចំនួនដែលរារាំងដល់ការរីកចំរើននៅកម្ពុជា និងពិភាក្សាពីវិធីផ្សេងៗសំរាប់ដោះស្រាយ ។ ជាបឋម គួរចងចាំថា បន្ទាប់ពីសង្គ្រាម និងការបំផ្លិចបំផ្លាញរបស់រយៈពេល ៣០ឆ្នាំ សន្តិភាព និងស្ថិរភាព បានកើតមានឡើងវិញនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៩ ហើយសមិទ្ធិផលដែលកម្ពុជាសំរេចបានចាប់ពីពេលនោះមកមានច្រើនខ្លាំងណាស់ ។

## ប្រភេទនៃកំណើននៅប្រទេសកម្ពុជា

ក្នុងមួយទសវត្សរ៍កន្លងទៅ ប្រទេសកម្ពុជាមានកំណើនខ្ពស់ ដែលអាចប្រៀបផ្ទឹមគ្នាបាននឹងប្រទេសមានសេដ្ឋកិច្ចលូតលាស់លឿននានានៅអាស៊ីខាងកើត ។ ប៉ុន្តែលទ្ធផលដែលកម្ពុជាសំរេចបានក្នុងការកាត់បន្ថយភាពក្រីក្រនៅមានកំរិតទាប គឺប្រហាក់ប្រហែលគ្នានឹងប្រទេសមានការលូតលាស់សេដ្ឋកិច្ចយឺតនៅភាគខាងត្បូងវាលខ្សាច់សាហារ៉ា ក្នុងទ្វីបអាហ្វ្រិក និងនៅអាស៊ីខាងត្បូង ។ ថ្វីបើសមហេតុផលដែរដែលថា លទ្ធផលខុសគ្នារវាងកម្ពុជា និងបណ្តាប្រទេសអាស៊ីខាងកើតជារួម គឺដោយសារប្រទេសទាំងនេះមានរយៈពេលវែងជាង សំរាប់លូតលាស់ក្តី

---

[1] For a fuller version of this brief please see Chapter 1 in the CDRI's Annual Development Review 2007-8.

[2] CDRI's publication includes: Fitzgerald, I. and S. So (2007): "Moving out of poverty: Trends in the community well-being and household mobility in nine Cambodian villages", CDRI, Phnom Penh.; and Ballard, B. (Editor) (2007): "We are living with worry all the times: A participatory poverty assessment of the Tonle Sap", CDRI, Phnom Penh. The World Bank study: World Bank (2007): 'Sharing prosperity', WB, Phnom Penh.

ក៏គំលាតនេះ អាចជាប់ទាក់ទងនឹងប្រភេទនៃកំណើននៅតាមតំបន់ ឬប្រទេសទាំងនេះ ហើយវាជះឥទ្ធិពលទៅលើល្បឿនកាត់បន្ថយភាពក្រីក្រ និងការប្រែប្រួលកំរិតវិសមភាព ។

មានការជជែកដេញដោលគ្នាមួយលើឯកសារនានាដែលមានស្រាប់ស្តីពី ប្រភេទខុសៗគ្នានៃកំណើន និងផលប៉ះពាល់ផ្សេងៗដែលប្រភេទនីមួយៗអាចបង្កទៅលើអ្នកក្រីក្រ និងអត្រាកាត់បន្ថយភាពក្រីក្រ ។ កំរិតដែលកំណើនអាចហូរចុះដល់អ្នកខាងក្រោមបានច្រើនប៉ុណ្ណាៗ វាជាប់ទាក់ទងនឹងប្រភេទនៃកំណើនសមាសភាពតាមវិស័យ និងចំណងតភ្ជាប់រវាងវិស័យខុសៗគ្នានៃសេដ្ឋកិច្ច ។ ប្រសិនបើកំណើនមានលក្ខណៈ "រាប់បញ្ចូល" ផលប្រយោជន៍នៃកំណើន ទំនងអាចបែងចែកបានធំទូលាយជាងនៅក្នុងសេដ្ឋកិច្ច ក្នុងនេះមានទាំងអ្នកក្រីក្រផង ។ កំណើនមានលក្ខណៈរាប់បញ្ចូល បើសិនជាវាមានរួមផ្សំដោយការបង្កើតឱកាសផ្សេងៗ ដែលគ្រប់ៗគ្នាអាចប្រើប្រាស់បាន ។

ការសិក្សាឆ្លងប្រទេសមួយចំនួនដែលធ្វើឡើងកាលពីពេលថ្មីៗ បានបង្ហាញថា បើគិតជាមធ្យម ការបែងចែកនៃកំណើនមិនមានភាពលំអៀងទេ ហើយអ្នកក្រ និងអ្នកធូរធារទទួលផលប្រយោជន៍ពីកំណើនបានស្មើៗគ្នា ។ ប៉ុន្តែករណីសិក្សាតាមប្រទេសនីមួយៗបានបង្ហាញថា រូបភាពជាមធ្យមនេះ មិនត្រឹមត្រូវទេ សំរាប់ករណីខ្លះៗ ដែលក្នុងនេះ អ្នកក្រីក្រប្រហែលទទួលផលប្រយោជន៍មិនបានច្រើនដូចអ្នកឯទៀតទេ ហើយក្នុង កាលៈទេសៈពិសេសខ្លះ ពុំមានចំណងទាក់ទងដោយផ្ទាល់រវាងកំណើន ហើយនិងការកាត់បន្ថយភាពក្រីក្រនោះទេ ។

**ចំណុចខ្វះខាតនៃកំណើននៅកម្ពុជា**

កម្ពុជាមាន កំណើនប្រាក់ចំណូលជាមធ្យមក្នុងមនុស្សម្នាក់ ប្រហែល ៧% ក្នុងទសវត្សរ៍ចុងក្រោយនេះ ។ ទោះយ៉ាងនេះក្តី ការចូលរួមតាមវិស័យនៃកំណើននេះ មានការខុសគ្នាខ្លាំង ។ វិស័យដែលមានកំណើនវិជ្ជមានថេរក្នុងរយៈពេលនេះគឺ វិស័យសេវាកម្ម និងឧស្សាហកម្ម ។ វិស័យកសិកម្មមានអត្រាកំណើនមិនទៀងទាត់ ហើយជួនកាលអវិជ្ជមានទៀតផង ។ យោងតាមការប្រមូលផ្តុំប្រជាជនកំរិតខ្ពស់នៅតាមតំបន់ជនបទ និងដំណើរការអន់ខ្សោយនៃវិស័យកសិកម្មក្នុងអំឡុងពេលនោះ ដូច្នេះគ្មានអ្វីគួរអោយភ្ញាក់ផ្អើលទេដែលថា អ្នកក្រីក្រនៅកម្ពុជាមិនបានទទួលប្រយោជន៍ច្រើនទេពីកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេស ។

ចំណុចខ្វះខាតមួយទៀតនៃកំណើននៅប្រទេសកម្ពុជា ពាក់ព័ន្ធនឹងកង្វះខាតចំណងទាក់ទង ទាំងនៅក្នុងវិស័យ និងរវាងវិស័យខុសៗគ្នា ។ សំរាប់កំណើនក្នុងវិស័យឧស្សាហកម្ម ទទួលបានការយកទុកដាក់កាន់តែខ្លាំងផ្នែកកាត់ដេរ និងផ្នែកសាងសង់ ជាកត្តាចំបងនៃការប្រែប្រួលនៅក្នុងវិស័យនេះ ។ ប៉ុន្តែផ្នែកទាំងពីរមានចំណងទាក់ទងខ្សោយ ជាមួយនឹងវិស័យដទៃទៀតក្នុងសេដ្ឋកិច្ច ហើយវាចូលរួមចំណែកភាគច្រើនក្នុងក្នុងការបង្កើតការងារប៉ុណ្ណោះ ។ ប្រហែលគ្នានេះដែរ សំរាប់វិស័យសេវាកម្ម កំលាំងជំរុញចំបងគឺ កំណើនយ៉ាងខ្លាំងក្នុងផ្នែកទេសចរណ៍ ។ ផ្នែកទេសចរណ៍ ក៏មានចំណងទាក់ទងខ្សោយដែរ ជាមួយវិស័យដទៃទៀតក្នុងសេដ្ឋកិច្ច ជាពិសេសវិស័យកសិកម្ម ។ ការរួមចំណែករបស់ផ្នែកទេសចរណ៍ដល់សេដ្ឋកិច្ច ក៏ភាគច្រើនជាការបង្កើតការងារ

នោះដែរ ។ ការសិក្សានាពេលថ្មីៗមួយរបស់វិទ្យាស្ថាន CDRI ដែលពិនិត្យពីឥទ្ធិពលកាត់បន្ថយភាពក្រីក្រនៃផ្នែកទេសចរណ៍ បានរកឃើញថា ផ្នែកនេះមិនបានដើរតួនាទីអ្វីសំខាន់ទេក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។[៣]

ចំណុចទាំងឡាយខាងលើនេះបង្ហាញថា កំណើននៅកម្ពុជាក្នុងពេលកន្លងមកពុំមានលក្ខណៈ "រាប់បញ្ចូល" ទេ ហើយផលប្រយោជន៍នៃកំណើនចែកចាយតែក្នុងចំណោមប្រជាជនមួយភាគតូចប៉ុណ្ណោះ ។ ហេតុផលដូចគ្នាក៏មានបញ្ជាក់ក្នុងការសិក្សាធំៗពីររបស់វិទ្យាស្ថាន CDRI ព្រមទាំងរបាយការណ៍ស្តីពីសមធម៌របស់ធនាគារពិភពលោកនៅឆ្នាំ២០០៧ ។ ការសិក្សាទាំងអស់នេះបានរកឃើញភស្តុតាងដែលបង្ហាញថា វិសមភាពនៅកម្ពុជាបានកើនឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយ ។ ថ្វីបើក្នុងលក្ខខណ្ឌខ្លះ រឿងនេះមិនចោទបញ្ហាអ្វីទេក្នុងរយៈពេលវែង ប៉ុន្តែជាការសំខាន់ ត្រូវរកឱ្យឃើញថា តើមានកំលាំងអ្វីខ្លះដែលបង្កកំណើនវិសមភាព ហើយកំណើននេះអាចធ្វើឱ្យខូចខាតប៉ុណ្ណាដល់ការអភិវឌ្ឍរយៈពេលវែង និងមានចីរភាពរបស់កម្ពុជា ។

ទាក់ទិននឹងអភិបាលកិច្ច ដើម្បីដោះស្រាយបញ្ហាមួយចំនួនដែលអ្នកស្រាវជ្រាវបានគូសរំលេចក្នុងផ្នែកនេះ វិធាន និងគោលនយោបាយរបស់រដ្ឋាភិបាលគួរតែច្បាស់លាស់ និងមានតម្លាភាព ។ យោងតាមក៏រិតសមត្ថភាពរបស់អ្នកកសាងគោលនយោបាយ ក្នុងការដោះស្រាយបញ្ហាគោលនយោបាយដ៏ច្រើននោះ ត្រូវមានការពិនិត្យយ៉ាងល្អិតល្អន់ និងការកំណត់អាទិភាពនៃគោលនយោបាយ ។ នៅដំណាក់កាលបច្ចុប្បន្ននៃប្រទេសកម្ពុជា ជាការប្រសើរបំផុតបើសិនរដ្ឋាភិបាលផ្តោតការប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីទទួលបានកំណើនដែលត្រឹមត្រូវ ហើយបើសិនសំរេចបានជោគជ័យក្នុងចំណុចនេះ នឹងអាចដោះស្រាយបាននូវបញ្ហាភាគច្រើនដែលកម្ពុជាកំពុងប្រឈមមុខ ជាពិសេសការប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ ។

ជាការសំខាន់ដែរដែលត្រូវបញ្ជាក់ថា ពុំមានអភិបាលកិច្ច រឺទំរង់ស្ថាប័នតែមួយល្អឯកនោះទេ ។ អ្នកផ្តល់ជំនួយអន្តរជាតិជាពិសេស ហាក់ដូចចង់ជំរុញឱ្យយើងទទួលយករចនាសម្ព័ន្ធអភិបាលកិច្ច ប្រភេទជាក់លាក់ណាមួយដោយមិនពិចារណាពីបទពិសោធន៍អន្តរជាតិដែលមានជោគជ័យក្នុងបរិបទនេះទេ ។ ក្នុងបរិបទតំបន់យើង ចំណុចខុសគ្នាមានច្បាស់ណាស់សំរាប់ប្រទេសអភិវឌ្ឍបានជោគជ័យមួយចំនួន ដូចជា សិង្ហបុរី និងកូរ៉េខាងត្បូង ក្នុងពេលកន្លងមក និងម៉ាឡេស៊ី ថៃ វៀតណាម និងចិន នាបច្ចុប្បន្ន ។

សហគមន៍ផ្តល់ជំនួយនៅកម្ពុជា អាចដើរតួនាទីសំខាន់ជាងនេះក្នុងការជំរុញកម្ពុជាឆ្ពោះទៅកាន់ការរីកចំរើនប្រកបដោយចីរភាព ។ យោងតាមធនធានមានក៏រិតសំរាប់អនុវត្ត គំរោងហេដ្ឋារចនាសម្ព័ន្ធចំបងៗ ដែលមានសារៈសំខាន់សំរាប់សេដ្ឋកិច្ច អាចដើរតួសកម្មក្នុងការគាំទ្រការវិនិយោគក្នុងវិស័យទាំងនេះ ជាពិសេស ផ្លូវថ្នល់ ថាមពល និងហេដ្ឋារចនាសម្ព័ន្ធខាងបច្ចេកវិទ្យាព័ត៌មាន ។

អនាគតសំរាប់ប្រទេសកម្ពុជាពិតជាភ្លឺស្វាង បើសិនមានការចាត់វិធានការដោះស្រាយចំណុចខ្វះខាតទាំងឡាយ ដូចបានរៀបរាប់ដោយសង្ខេបនេះ ។

[3] Hing, V. and S. Tuot (2007): 'Pro-poor tourism: Siem Reap case study' in CDRI (2007): 'Pro-poor tourism in the Greater Mekong Sub-region', CDRI, Phnom Penh.